ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# គម្រោងកែលម្អការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់

P169930

និងហិរញ្ញប្បទានបន្ថែម P181396

# ផែនការស្តីពីការចូលរួមរបស់ភាគីពាក់ព័ន្ធ

វិច្ឆិកា ២០២៣

## សេចក្តីសង្ខេប

ឯកសារផែនការស្តីពីការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEP) ត្រូវបានរៀបចំឡើងដោយក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទសម្រាប់ «គម្រោងកែលម្អការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់» មានការចូលរួមពីមន្ត្រីការិយាល័យ សង្គមនិងបរិស្ថាន និងមានការគាំទ្រពីទីប្រឹក្សាបច្ចេកទេសថ្នាក់ជាតិ និងអន្តរជាតិ។ ផែនការនេះ អនុវត្តចំពោះការវិនិយោគទាំងអស់នៅក្នុងគម្រោង និងហិរញ្ញប្បទានបន្ថែមដែលផ្តល់ហិរញ្ញប្បទានដោយធនាគារពិភពលោក (WB)។ ឯកសារ SEP ត្រូវបានរៀបចំឡើងស្របតាមគោលការណ៍ណែនាំនៃក្របខ័ណ្ឌបរិស្ថាន និងសង្គម របស់ធនាគារពិភពលោក ដោយត្រូវបានចាត់ទុកថាជាឯកសារអាចបានកែសម្រួល និងធ្វើបច្ចុប្បន្នភាពស្របតាមស្ថានភាពជាក់ស្តែងនៃបម្រែបម្រួលគម្រោង។ ឯកសារ SEP ចុងក្រោយនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងសម្រាប់ការផ្តល់ហិរញ្ញប្បទានបន្ថែម (AF)។ សេចក្តីសង្ខេបនេះ មិនបានពិពណ៌នាលម្អិតឡើយ សម្រាប់ការស្វែងយល់លម្អិតពីឯកសារ SEP សូមអានឯកសារ SEP ពេញលេញ។

## ព័ត៌មានគម្រោងសង្ខេប

គម្រោងកែលម្អការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងការផ្តល់ហិរញ្ញប្បទានបន្ថែម របស់ធនាគារពិភពលោក គាំទ្រដល់ការកែលម្អផ្លូវថ្នល់ ធានាភាពធន់នឹងការប្រែប្រួលអាកាសធាតុ មានភាពងាយស្រួល និងប្រើប្រាស់បានគ្រប់រដូវកាល ស្ថិតនៅក្នុងខេត្តគោលដៅចំនួន០៣ រួមមាន៖ ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ។ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ រួមចំណែកក្នុងការកែលម្អស្ថានភាពផ្លូវ និងលើកកម្ពស់សុវត្ថិភាពធ្វើដំណើរ តាមរយៈការក្រាលកៅស៊ូពីរជាន់ និងបេតុង ព្រមទាំងសំណង់សិល្បការគ្រប់ប្រភេទសំដៅធានាប្រើប្រាស់បានយូរអង្វែង ដែលជាវិធានការបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ។

សមាសភាពទី១៖ ផ្តល់ល់ហិរញ្ញប្បទានក្នុងការស្តារឡើងវិញផ្លូវប្រវែង ១៣០ គីឡូម៉ែត្រ ស្ថិតនៅក្នុងខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ អនុវត្តដោយក្រសួងសាធារណការ និងដឹកជញ្ជូន និងសមាសភាពទី២៖ ផ្តល់ហិរញ្ញ-ប្បទានក្នុងការស្តារឡើងវិញផ្លូវជនបទប្រវែង ២៧០ គីឡូម៉ែត្រ ស្ថិតនៅក្នុងខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ អនុវត្តដោយក្រសួងអភិវឌ្ឍន៍ជនបទ ។ ការផ្តល់ហិរញ្ញប្បទានបន្ថែម មិនបានកែប្រែទំហំការងារ ឬផ្លាស់ប្តូរប្រភេទការងារ និងទីតាំងគម្រោងឡើយពោលគឺគ្រាន់តែបំពេញបន្ថែមនូវកង្វះហិរញ្ញប្បទាន ដែលបានស្នើសុំ ដូចនេះ ឯកសារ SEP នៅតែរក្សា និងមានសុពលភាពដដែលសម្រាប់ការផ្តល់ហិរញ្ញប្បទានបន្ថែម។

## ផែនការស្តីពីការចូលរួមរបស់ភាគីពាក់ព័ន្ធ

ឯកសារ SEP ត្រូវបានរៀបចំឡើងដើម្បីធានាថាគ្រប់ភាគីពាក់ព័ន្ធ និងសហគមន៍ បានជ្រាបអំពីដំណើការ និងចូលរួមសហការគ្រប់ដំណាក់កាលនៃការរៀបចំ និងអនុវត្តគម្រោង ដោយទទួលយករាល់មតិកែលម្អ និងព័ត៌មានត្រឡប់ ប្រកបដោយបរិយាប័ន្ន ម្យ៉ាងទៀតឯកសារនេះ បង្កើតឱ្យមានកាលានុវត្តភាពនៃតួនាទី របស់ស្ត្រី

និងក្រុមជនងាយរងគ្រោះ ក្នុងកិច្ចពិគ្រោះយោបល់ និងការសម្រេចចិត្តនានាក្នុងការដំណើការអនុវត្តគម្រោង។ ជាមួយគ្នានេះ គម្រោងក៏ទទួលស្គាល់ពីសារៈសំខាន់ក្នុងការធានាឱ្យប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ចូលរួមក្នុងការអនុវត្តវិធានការកាត់បន្ថយ និងកម្មវិធីសុវត្ថិភាពផ្លូវថ្នល់ ព្រមទាំងបន្តការតាមដានសកម្មភាព អនុវត្តគម្រោង។

ឯកសារ SEP បញ្ជាក់អំពីភាគីពាក់ព័ន្ធដែលរងផលប៉ះពាល់÷ អ្នកដែលរងផលប៉ះពាល់ផ្ទាល់ដោយការសាងសង់ផ្លូវ និងអ្នកពាក់ព័ន្ធដែលចាប់អារម្មណ៍ សំដៅដល់អ្នកដែលមានចំណាប់អារម្មណ៍ ឬកង្វល់ក្នុងការអនុវត្តគម្រោង ។ ឯកសារ SEP នឹងបង្ហាញអំពីវិធីសាស្ត្រ និងពេលវេលាជាក់លាក់ ដើម្បីចូលរួមជាមួយពួកគេនៅដំណាក់កាល ផ្សេងៗគ្នានៃការអនុវត្តគម្រោង។ ឯកសារ SEP ក៏ពិពណ៌នាអំពីប្រភេទព័ត៌មានដែលនឹងត្រូវផ្សព្វផ្សាយ ពេលវេលាពិគ្រោះយោបល់ និងទស្សនៈ ឬកង្វល់របស់ភាគីពាក់ព័ន្ធ ត្រូវបានយកមកពិចារណាដោះស្រាយតាមរយៈយន្តការបណ្តឹងសារទុក្ខ (GRM)។